# ការរំខានដល់កិច្ចដំណើរការស្វែងរកយុត្តិធម៌ ជូនប្រជាជនកម្ពុជា

ប្រជាជនកម្ពុជាប្រមាណជាងពីរលានបានស្លាប់បាត់បង់ជីវិតដោយសារ ការសម្លាប់ ការបង្អត់អាហារ ការដាក់កម្រិតឲ្យធ្វើការជាទម្ងន់ ការធ្វើទារុណកម្ម ។ល។ ដែលត្រូវបានប្រព្រឹត្តដោយខ្មែរក្រហម នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ចំណែកប្រជាជនកម្ពុជាមួយចំនួនធំទៀត មានទាំងជនរងគ្រោះ និងកម្មាភិបាលខ្មែរក្រហមថ្នាក់ក្រោមជាច្រើនដែលនៅរស់រានមានពីជីវិតពីរបបដ៏សាហាវយង់ឃ្នងនេះគឺនៅតែបន្តទទួលរងនូវការឈឺចាប់ទាំងផ្លូវកាយ និងផ្លូវចិត្ត ដោយសារធ្លាប់ទទួលរងការងារជាទម្ងន់ ការបែកបាក់គ្រួសារ និងការបំបាក់ស្មារតី ។ ភាពមិនអើពើចំពោះ ការស្រេកឃ្លានដែលជាតម្រូវការមូលដ្ឋានរបស់មនុស្សជាតិ និងការរំលោភសិទ្ធិមនុស្ស បានកើតពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ ។

តាមរយៈបុព្វកថានៃកិច្ចព្រមព្រៀងរវាង រាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ គឺភាគីទាំងពីរបានទទួលស្គាល់ចំពោះស្ថានភាពទាំងនេះ ព្រមទាំងសម្តែងឆន្ទៈស្វែងរកយុត្តិធម៌ជូនប្រជាជនកម្ពុជា តាមរយៈការធ្វើកិច្ចសហប្រតិបត្តិការបង្កើតតុលាការ ដើម្បីនាំយកមេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋ មកទទួលខុសត្រូវចំពោះមុខច្បាប់ ។

ដើម្បីបំពេញឆន្ទៈរបស់ភាគីទាំងពីរក្នុងការស្វែងរកយុត្តិធម៌ជូនប្រជាជនកម្ពុជា អង្គជំនុំជម្រះសាលាដំបូងនៃតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម បានខិតខំប្រឹងប្រែងបំពេញការងាររបស់ខ្លួនយ៉ាងលំបាក និងប្រឈមគ្រប់ឧបសគ្គក្នុងការនាំខ្លួនអតីតមេដឹកនាំជាន់ខ្ពស់ រួមមាន នួន ជា អតីតប្រធានសភាតំណាងប្រជាជន, ខៀវ សំផន អតីតប្រធានគណៈប្រធានរដ្ឋ និង អៀង សារី អតីតឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេស មកធ្វើការជំនុំជម្រះទោស ។ អង្គជំនុំជម្រះសាលាដំបូងបានប្រឈមមុខនឹងការរៀបចំនិងការគ្រប់គ្រងដំណើរការជំនុំជម្រះក្តីលើសំណុំរឿងដែល មានភាពស្មុគស្មាញ មានទំហំធំ និងអង្គហេតុឧក្រិដ្ឋកម្មកើតពេញផ្ទៃប្រទេស ។ ប្រឈមមុខដោះស្រាយចំពោះការទាមទារស្ទើរគ្រប់យ៉ាងរបស់ក្រុមមេធាវីការពារក្តី ដែលសុទ្ធសឹងជាអ្នកមានសមត្ថភាពក្នុងការការពារកូនក្តីរបស់ខ្លួន ។ លើសពីនេះទៀតអង្គជំនុំជម្រះបានបង្ខំចិត្តពន្យារពេលកិច្ចដំណើរការរបស់ខ្លួនម្តងហើយម្តងទៀតៗ ដោយសារជនជាប់ចោទមានបញ្ហាសុខភាពដែលបណ្តាលមកពីវ័យចាស់ជរា ។ រហូតមកដល់ពេលនេះ អង្គជំនុំជម្រះសាលាដំបូងគ្មានជម្រើសអ្វីក្រៅពីសម្រេចពន្យារពេលសវនាការឡើយ ប្រសិនបើជនជាប់ចោទណាម្នាក់មានបញ្ហាសុខភាពមិនអាចចូលរួមសវនាការបាន ហើយជននោះពុំបានលះបង់សិទ្ធិមានវត្តមានក្នុងកិច្ចដំណើរការសវនាការ ។


66 Preah Sihanouk Blvd. • P.O.Box 1110 • Phnom Penh • Cambodia
t (855-23) 211-875 • f (855-23) 210-358 • dccam@online.com.kh • www.dccam.org

ថ្ងៃទី៥ ខែមីនា ឆ្នាំ២០១៣

ឥឡូវបញ្ហាកង្វះខាតថវិការសម្រាប់បើកប្រាក់បៀវត្សជូនបុគ្គលិកខ្មែរ បានក្លាយជាឧបគ្គថ្មីមួយផ្សេងទៀតក្នុងការរាំងស្ទះដល់កិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង ។ កាលពីថ្ងៃទី៤ ខែមីនា ឆ្នាំ២០១៣ ក្រុមបុគ្គលិកខ្មែរផ្នែកបកប្រែភាសាបានធ្វើពហិការមិនព្រមចូលបំពេញការងារ ដោយសារខ្លួនពុំទាន់ទទួលបានប្រាក់បៀវត្សអស់រយៈពេល៣ខែកន្លងមកហើយ នៅខណៈដែលបុគ្គលិកអន្តរជាតិពុំមានបញ្ហានេះដូចខ្លួន ។ នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៣ រដ្ឋាភិបាលចក្រអង់គ្លេសបានសន្យាផ្តល់ជំនួយប្រមាណ ២,២ លានដុល្លារអាមេរិកដល់ភាគីអន្តរជាតិ នៅខណៈពេលដែលភាគីកម្ពុជាមានការខ្វះខាតថវិការសម្រាប់បើកប្រាក់បៀវត្សជូនបុគ្គលិកចាប់តាំងពី ខែធ្នូ ឆ្នាំ២០១២ មកម្ល៉េះ ។ ពិតប្រាកដណាស់ អង្គជំនុំជម្រះនឹងមិនអាចដំណើរការជំនុំជម្រះក្តីរបស់ខ្លួនបានឡើយ ប្រសិនបើគ្មានអង្គភាពបកប្រែភាសា ព្រោះតាមសមាភាពរបស់អង្គជំនុំជម្រះ និងភាគីទាំងអស់ គឺតម្រូវឲ្យមានការបកប្រែជាភាសាខ្មែរ ភាសាបារាំង និង ភាសាអង់គ្លេស ។ ទោះបីជាយ៉ាងណា វាពុំមានជាបញ្ហាដែលពុំអាចដោះស្រាយបាន ដែលតម្រូវឲ្យអង្គជំនុំជម្រះសាលាដំបូងបង្ខំចិត្តផ្អាកកិច្ចដំណើរការនីតិវិធីរបស់ខ្លួន ដូចក្នុងករណីជនជាប់ចោទមានបញ្ហាសុខភាពឡើយ ។ វាពុំគួរជាឧបសគ្គរាំងដល់កិច្ចដំណើរការរបស់ជំនុំជម្រះក្នុងការស្វែងរកយុត្តិធម៌ជូនប្រជាជនកម្ពុជាដែលបានស្លាប់រាប់លាននាក់ ដោយសារទទួលរងនូវអំពើនៃការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់មនុស្សធម៌អន្តរជាតិឡើយ ។ ភាគីកម្ពុជា និង អង្គការសហប្រជាជាតិមានភារកិច្ចរួមគ្នាក្នុងការធានានូវការប្រព្រឹត្តទៅដោយរលូនរបស់អង្គជំនុំជម្រះ ។

ដោយៈ ចាន ប្រាថ្នា

ពិនិត្យ និងកែសម្រួលដោយៈ ឆាំង យុ